**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ៩០៨ ឧស.អគន.ការិយា

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤

# សេចក្តីជូនដំណឹង

យោងតាមសេចក្តីជូនដំណឹងលេខ ៥១៦ សជណ.សរ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ ស្តីពីលទ្ធផលវេទិកាការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៧ នាថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៤ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានកិត្តិយសសូមជំរាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជាប្រធានរោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មទាំងអស់ មេត្តាជ្រាបថា ក្រសួងបានរៀបចំការិយាល័យច្រកចេញ-ចូលតែមួយនៅទីស្តីការក្រសួង ដើម្បីទទួលបម្រើសេវាក្នុងការចុះបញ្ជី បង្កើត បន្ត ផ្តល់វិញ្ញាបនបត្រ អាជ្ញាប័ណ្ណ និងឯកសារដែលពាក់ពន្ធ័វិស័យឧស្សាហកម្ម និងសិប្បកម្មដទៃទៀត ចាប់ពីថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៤ នេះតទៅ ។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សង្ឃឹមជឿជាក់ថា ការអញ្ជើញមកដាក់ពាក្យស្នើសុំឯកសារពាក់ព័ន្ធ ដូចបានជម្រាបជូនខាងលើនៅការិយាល័យច្រកចេញ-ចូលតែមួយ នៃទីស្តីការក្រសួង ដែលមានអាស័យដ្ឋាននៅអគារលេខ ៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ របស់ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី អាចនឹងកាត់បន្ថយបាននូវភាពអសកម្ម និងបាតុភាពផ្សេងៗ បង្កឡើងដោយភ្នាក់ងារកណ្តាល ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី មេត្តាជ្រាប និងសហការឱ្យបានជិតស្និទ្ធ ដើម្បីរួមគ្នាកែលម្អការផ្តល់សេវារបស់ការិយាល័យច្រកចេញ-ចូលតែមួយ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

ចំពោះព័តមានលម្អិត ឬបាតុភាពបង្កឡើងនៅច្រកចេញ-ចូលតែមួយនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមមេត្តាទំនាក់ទំនងតាមទូរសព្ទ័លេខ **០១២ ៧១៧ ៩៣៥/០១២ ៤៥៩ ៥៨៦** និងអ៊ីម៉ែល k.sedhika@yahoo.com ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ហេង សុខគង់**